សហព័ន្ធខ្មែរកម្ពុជាក្រោម
KHMERS KAMPUCHEA-KROM FEDERATION
Asia – Australia – Europe – North America
P.O. Box 0193 • Pennsauken • NJ • 08110 • U.S.A. • Tel: (856) 655-3838 • Fax: (856) 583-1503
http://www.khmerkrom.org • Email: info@khmerkrom.org

# សេចក្តីថ្លែងការណ៍

## (ខួប ៦៨ ឆ្នាំ ថ្ងៃបារាំងកាត់ដែនដីកម្ពុជាក្រោមឲ្យវៀតណាម)

# ៦៨ ឆ្នាំ ក្តីសង្ឃឹមនៃសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង

សូមថ្វាយបង្គំចំពោះព្រះសង្ឃគ្រប់អង្គជាទីគោរពដ៏ខ្ពង់ខ្ពស់ !

សូមគោរពបងប្អូនជនរួមជាតិទាំងអស់ និងសមាជិក សមាជិកា ព្រមទាំងថ្នាក់ដឹកនាំ នៃសហព័ន្ធខ្មែរកម្ពុជាក្រោមនៅជុំវិញពិភពលោក ជាស្រឡាញ់រាប់អាន !

នៅថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៧ នេះ សាខាសហព័ន្ធខ្មែរកម្ពុជាក្រោមទូទាំងពិភពលោក បានប្រារព្ធពិធីខួប ៦៨ ឆ្នាំ ដើម្បីរំឭកដល់ថ្ងៃដែលបារាំងបានកាត់ដែនដីកម្ពុជាក្រោម ជាដីខ្មែរមួយភាគធំ នៃប្រទេសកម្ពុជាឱ្យទៅវៀតណាមបន្តធ្វើអាណានិគមបន្តលើប្រជាជាតិខ្មែរក្រោម ។

សេចក្តីប្រកាសច្បាប់ លេខ ៤៩-៧៣៣ របស់ប្រធានាធិបតីបារាំង វ៉ែនសង់ អូរិយោល (Vincent Auriol) នៅថ្ងៃទី 0៤ ខែមិថុនា ឆ្នាំ ១៩៤៩ ក្នុងការប្រគល់ដែនដីកម្ពុជាក្រោម ឱ្យទៅជារដ្ឋចំណុះវៀតណាម ជាសន្ធិសញ្ញាខុសច្បាប់មួយញែកដែនដីកម្ពុជាក្រោមឱ្យចេញពីខណ្ឌសីមានៃប្រទេសកម្ពុជា និងបានកាត់វាសនាប្រជាជាតិខ្មែរក្រោមវាល់លាននាក់ឱ្យឃ្លាតចេញពីការគ្រប់គ្រងរបស់រដ្ឋាភិបាលនៃប្រទេសកម្ពុជា ហើយបានក្លាយទៅជាជនជាតិភាគតិចលើដីកំណើតរបស់ខ្លួននៅក្រោមនឹមអាណានិគមថ្មីរបស់វៀតណាម ។

៦៨ ឆ្នាំនៅក្រោមនឹមអាណានិគមរបស់វៀតណាម ប្រជាជាតិខ្មែរក្រោមបានក្លាយទៅជាកូនកំព្រាគ្មានមេបាថែរក្សារងទុក្ខឈឺចាប់ខ្លោចផ្សាឥតមានពេលស្រាកស្រាន្ត ។ ព្រះសង្ឃ និងបញ្ញវន្តខ្មែរក្រោមត្រូវចាប់ដាក់ពន្ធនាគារ និងធ្វើទារុណកម្ម ប្រវត្តិសាស្ត្រកម្ពុជាក្រោមត្រូវកែបំភ្លៃដើម្បីលាងខួរក្បាលយុវជនខ្មែរក្រោមឱ្យភ្លេចកំណើតជាខ្មែរ គ្មានសិទ្ធិនៃការបញ្ចេញមតិ និងបង្កើតអង្គការសមាគម និងជីវភាពកាន់តែក្រីក្រជាដើម ។

ទោះបីកម្ពុជាក្រោមនៅក្រោមនឹមអាណានិគមវៀតណាមអស់ ៦៨ ឆ្នាំហើយយ៉ាងក៏ដោយ តែយើងនៅតែមានក្តីសង្ឃឹមជានិច្ច ដោយសារនៅក្នុងសតវត្សរ៍ទី ២១ នេះ ជាសករាជនៃ “**សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង**” របស់ជនជាតិដើមទូទាំងពិភពលោក ។ សហព័ន្ធខ្មែរ

កម្ពុជាក្រោមនឹងបន្តធ្វើការតស៊ូដោយសន្តិវិធី និងអហិង្សានៅលើឆាកអន្តរជាតិដើម្បីជម្រុញឱ្យប្រជាជាតិខ្មែរក្រោមនៅក្នុងស្រុកបានស្គាល់ និងចេះប្រើប្រាស់នូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួនហើយឈានទៅរក **"សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង"** ក្នុងនាមជាជនជាតិដើមនៃដែនដីកម្ពុជាក្រោម ។

សូមឱ្យថ្ងៃប្រវត្តិសាស្ត្រដ៏ឈឺចាប់នេះ ក្លាយទៅមេរៀនសម្រាប់ថ្នាក់ដឹកនាំ និងប្រជាជាតិខ្មែរគ្រប់ជំនាន់នៅក្នុងប្រទេសកម្ពុជាឱ្យចេះការពារជាតិ និងទឹកដីរបស់ខ្លួនកុំឱ្យបាត់បង់ទៅបរទេសតទៅទៀត ។ ទិវាដ៏ឈឺចាប់នេះ នឹងក្លាយទៅកម្លាំងចិត្តស្នេហាជាតិដ៏មុះមុតឋិតនៅក្នុងសតិអារម្មណ៍របស់ថ្នាក់ដឹកនាំ និង សមាជិកនៃសហព័ន្ធខ្មែរកម្ពុជាក្រោមនៅជុំវិញពិភពលោកឱ្យបន្តការតស៊ូដោយអហិង្សាតទៅមុខទៀត ដើម្បីនាំមកនូវ **សិទ្ធិសេរីភាព យុត្តិធម៌** និង **សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង** ជូនប្រជាជាតិខ្មែរក្រោមក្នុងស្រុក សព្វថ្ងៃ ។

សូមជនរួមជាតិ ថ្នាក់ដឹកនាំ និងសមាជិក សមាជិកា នៃសហព័ន្ធខ្មែរកម្ពុជាក្រោមទទួលនូវសេចក្តីគោរពរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំព្រះករុណា ខ្ញុំបាទ ។

សហរដ្ឋអាមេរិក ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៧

**ប្រាក់ សេរីវុឌ្ឍ**

ប្រធានប្រតិបត្តិ នៃសហព័ន្ធខ្មែរកម្ពុជាក្រោម